គម្រោង "បន្សាំនឹងភាពរាំងស្ងួតតាមរយៈការពង្រឹងនូវការទទួលបានទឹកស្រោចស្រព និងការអនុវត្តបច្ចេកទេសកសិកម្មដែលមានភាពបន្សាំ" ក្រោមការឧបត្ថម្ភថវិកាដោយស្ថានទូតស៊ុយអែត ប្រចាំប្រទេសកម្ពុជា តាមរយៈកម្មវិធីUNDP GEF SGP-CCBAP អនុវត្តដោយអង្គការយូរីដូHURREDO

# លក្ខខណ្ឌការងារនៃការវាយតម្លៃគម្រោង

## ១. ពណ៌នាពីប្រវត្តគម្រោង

- រៀងរាប់ដោយសង្ខេបពីប្រវត្តិអង្គការ
- បង្ហាញពី៖

    ក)គោលបំណងរួមនៃគម្រោង

    ខ)គោលបំណងជាក់លាក់និមួយៗ

## ២. ការវាយតម្លៃគំរោង

ការរៀបចំវាយតម្លៃបញ្ចប់គម្រោងនេះធ្វើឡើងដោយផ្អែកលើគោលការរៀនសូត្រជាមូលដ្ឋានតាមរយៈការចូលរួមរបស់សហគមន៍ អ្នកពាក់ពន្ធ័ក្នុងការកសាងគម្រោង អនុវត្តន៏ផែនការសកម្មភាព និងការចែករំលែកព័ត៌មាន។ ដោយការអនុវត្តគម្រោងមានការជាប់ពាក់ពន្ធ័ជាមួយដៃគូរជាច្រើនរួមទាំងមន្ត្រីសហការពីស្ថាប័ន័ថ្នាក់ក្រោមជាតិដូចនេះការវាយតម្លៃបញ្ចប់គម្រោងទាមទាអោយមានការចូលរួមផ្តល់គំនិតយោបល់ក្នុងដំណើការនេះ។

ទន្ទឹមនឹងនេះដែរ ស្ថានទូតស៊ុតអែតតាមរយៈ កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា(UNDP) នឹងដឹងពីភាពជោគជ័យពីការអនុវត្តគម្រោងដែលមានលក្ខណៈបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុប្រកបដោយនិរន្តរភាព ព្រមទាំងការអនុវត្តល្អផ្សេងៗដែលអាចជាគំរូសំរាប់ការគាំទ្របច្ចេកទេសកាន់តែប្រសើរថែមទៀតដល់អង្គការដៃគូរនានានៅពេលខាងមុខ។ លទ្ធផលនៃការវាយតម្លៃនឹងជួយដល់អង្គការដៃគូរខ្លួនឯងបានឆ្លុះបញ្ចាំងពីចំនុចខ្លាំង និងចំនុចខ្សោយពីការអនុវត្តគម្រោងដើម្បីចងក្រងជាឯកសារទុកសំរាប់ការកសាងគម្រោងពេលក្រោយ និងជាសក្តានុពលដើម្បីស្វែងរកម្ចាស់ជំនួយផ្សេងៗទៀត។

### របាយការណ៍រីកចំរើន និងការត្រួតពិនិត្យ

ដើម្បីផ្ទៀងផ្ទាត់ពីការរីកចំរើនលើសកម្មភាពគម្រោងដែលបានអនុវត្ត ព័ត៌មានដែលមានស្រាប់ដូចជារបាយការណ៍រីកចំរើនតាមដំណាក់កាលនៃការបង្វេរថវិកាអនុលោមតាមកិច្ចព្រមព្រៀងរបស់អង្គការដៃគូ អនុសាសន៍ដែលបានកត់ត្រាទុកអំឡុងពេលចុះត្រួតពិនិត្យរបស់ម្ចាស់ជំនួយតំរូវឲ្យទីប្រឹក្សាឯករាជ្យទទួលយកជាឯកសារ និងជាជំនួយក្នុងការវាយតម្លៃគម្រោង។

## ៣. គោលបំណងនៃការវាយតម្លៃរបស់ទីប្រឹក្សាឯករាជ្យ

**គោលបំណង**

ទីប្រឹក្សាឯករាជ្យនឹងត្រូវធ្វើការវាយតម្លៃទៅលើប្រសិទ្ធភាព និងផលប៉ះពាល់ដែលស្តែងចេញពីការអនុវត្តគម្រោងដោយផ្អែកលើគោលបំណងរបស់គម្រោង។

**វត្ថុបំណង**

1. ធ្វើការប្រៀបធៀបពិន្ទុនៃការវាយតម្លៃការកាត់បន្ថយភាពងាយរងគ្រោះ (VRA) មុនពេលគម្រោងអនុវត្តនិងក្រោយពេលអនុវត្តគម្រោងដែលបានដឹកធ្វើដោយអង្គការដៃគូរ
2. ប្រសិទ្ធភាពនៃការកសាងសម្ថភាពបន្សុំាការប្រែប្រួលអាកាសធាតុ ទៅដល់សហគមន៍ឬ ក្រុមដែលបានបង្កើត និងក្រុមដែលមានស្រាប់
3. កំរិតនៃការបញ្ជ្រាបផែនការការសកម្មភាពគម្រោងបន្សុំានិងការប្រែប្រួលអាកាសធាតុទៅនឹងផែនការវិនិយោគឃុំ
4. លទ្ធផលនៃការចងក្រងការអនុវត្តន៍គំរោងបានល្អមេរៀននានាដើម្បីកែលម្អគម្រោង និងផ្តល់ជាអនុសាសន៍សំរាប់ជាគោលគំនិតក្នុងការរៀបចំ និងអនុវត្តក្រោយៗទៀត។

**ទំហំការងារ**

- ទីប្រឹក្សាឯករាជ្យត្រូវការពិនិត្យលើឯកសារពាក់ពន្ធ័ដែលផ្តល់ដោយអង្គការសាមុី
- ដំណើការនៃការវាយតម្លៃរួមមាន ចុះសំភាសន៍នឹងក្រុមពិភាក្សា ប្រជាជនគោលដៅ ក្រុមសន្សំ ប្រជានេសាទ សហគមន៍ ព្រៃឈើ គណៈកម្មការសហព័ន្ធសហគមន៍នេសាទ គណៈកម្មការ សហគមន៍ប្រើប្រាស់ទឹក ក្រុមប្រឹក្សាឃុំនៃឃុំគោលដៅគម្រោង និងលេខាធិការដ្ឋានជំនួយខ្នាតតូចនៃកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)
- ទីប្រឹក្សាឯករាជ្យនឹងត្រូវរៀបចំរបាយការណ៍វាយតម្លៃគម្រោងដែលពណ៌នាពី ដំណើការនៃការវាយតម្លៃ របកគំហើញ បទពិសោធន៍ដែលរៀនសូត្របានអំឡុងពេលអនុវត្តគម្រោងនិងផ្តល់អនុសាសន៍
- របាយការណ៍វាយតម្លៃគម្រោងត្រូវសរសេរជា ភាសាខ្មែរ ១ច្បាប់ នឹង ១ច្បាប់ជាភាសារ អង់គ្លេស
- ទីប្រឹក្សាឯករាជ្យត្រូវរៀបចំបទបង្ហាញ និងពន្យល់ពីរបកគំហើញនៃការវាយតម្លៃតាមការស្នើសុំរបស់គម្រោងសាមុី

## ៤. វិធីសាស្រ្តនៃការវាយតម្លៃ

- ដើម្បីបង្ហាញពីភាពឯករាជ្យ និងតម្លាភាពតម្រូវឲ្យទីប្រឹក្សាប្រើ ឧបករណ៍វាយតម្លៃដែលមានការចូលរួមពីអ្នកពាក់ពន្ធ័ ដើម្បីត្រួតពិនិត្យ និងយល់ព្រម
- **ពេលវេលា៖** បង្កើតកាលវិភាគ និងសកម្មភាពសំរាប់រយៈពេលចុះធ្វើការវាយតម្លៃ
- **ការវិភាគព័ត៌មាន៖** ឧបករណ៍វាស់វែងសមត្ថភាពក្រុម នឹងការឆ្លុះបញ្ចាំងជាមួយសហគមន៍ អំពីចំនុចវិជ្ជមាន ចំនុចអវិជ្ជមាន ក៍ដូចជាចំនុចចាប់អារម្មណ៍ ដែលនឹងត្រូវប្រើប្រាស់សំរាប់ការវិភាគព័ត៌មានបែបគុណភាព ។ ឧបករណ៍ផ្សេងៗអាចត្រូវបានប្រើនៅក្នុងការវាយតម្លៃនេះ ដោយមានការពិភាក្សាជាមួយសហគមន៍គោលដៅ អ្នកទទួលផលពីគម្រោងនិងអ្នកអនុវត្តគម្រោង នឹងចូលរួមនៅក្នុងការផ្តល់ការសន្និដ្ឋាន និងអនុសាសន៍ ។

## ៥. លក្ខណៈសម្បត្តិនៃទីប្រឹក្សា

**ការសិក្សា**

បញ្ចប់ថ្នាក់បរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងគម្រោង បរិស្ថាន ការសិក្សាផ្នែកអភិវឌ្ឍន៍ ឬកសិកម្ម

**បទពិសោធន៍**

- មានបទពិសោធន៍យ៉ាងតិច៥ឆ្នាំទាក់ទងនិងការវាយតម្លៃគម្រោងផ្នែកប្រែប្រួលអាកាសធាតុ អភិវឌ្ឍន៍ជនបទ និងកសិកម្ម។
- មានបទពិសោធន៍យ៉ាងតិច២ឆ្នាំទាក់ទង និងការបង្កើតប្រពន្ធ័តាមដាននិងវាយតម្លៃគម្រោង
- មានបទពិសោធន៍គ្រប់គ្រាន់ក្នុងការស្រាវជ្រាវបែបការចូលរួម
- មានបទពិសោធន៍ក្នុងការ ប្រមូលព័ត៌មាន វិភាគ និងសរសេររបាយការណ៍
- មានបទពិសោធន៍ក្នុងការគ្រប់គ្រងគម្រោង
- មានបទពិសោធន៍ ព្រមទាំងចំណេះដឹងទាក់ទងការបន្សាំ និងការកាត់បន្ថយការប្រែប្រួលអាកាសធាតុ

## ៦. តម្រូវការឯកសារ

ទីប្រឹក្សាឯករាជ្យទាំងអស់ដែលចាប់អារម្មណ៍សូមផ្ញើឯកសារទាំងពីរដូចខាងក្រោមមកការិយាល័យអង្គការដៃគូរ

- ប្រវត្តិរូបសង្ខេប រួមទាំងតម្លៃដែលរំពឹងទុក
- ឧទាហរណ៍ការងារវាយតំលៃគំរោងដែលធ្លាប់ធ្វើកន្លងមក

**បញ្ជាក់៖** អ្នកវាយតម្លៃ ឬក្រុមការងារ មិនមែនជាអ្នកដែលបានចូលរួមដោយផ្ទាល់នៅក្នុងការរៀបចំគម្រោង អនុវត្តន៍គម្រោង ឬមានបេក្ខភាពក្នុងជួរក្រុមប្រឹក្សាភិបាលរបស់អង្គការទេ។